**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ១២១៨/២៧

ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការលើកលែងកាតព្វកិច្ចពាក់ម៉ាស់ ក្នុងខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ។

**យោង** ៖ សារសម្លេងពិសេសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ ស្តីពីការសម្រេចលើកលែងកាតព្វកិច្ចពាក់ម៉ាស់ ក្នុងខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្តទាំងអស់ មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចលើកលែងនូវកាតព្វកិច្ចពាក់ម៉ាស់ នៅខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ។ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលនេះ ក្រសួងសុខាភិបាលសូមស្នើដល់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអាជ្ញាធរខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ត្រូវធ្វើការណែនាំដល់សាធារណជនទាំងអស់នៅក្នុងភូមិសាស្ត្រស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អំពីការលើកលែងកាតព្វកិច្ចពាក់ម៉ាស់ និងការបន្តអនុវត្តវិធានការចំបាច់នានា ដូចខាងក្រោម៖

១. ប្រជាជនទាំងអស់ដែលរស់នៅក្នុងខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ និងប្រជាជនដែលធ្វើដំណើរពីរាជធានី-ខេត្តដទៃទៅកាន់ខេត្តទាំង៤ ពុំតម្រូវឱ្យពាក់ម៉ាស់ទៀតឡើយ ដោយប្រជាជនទាំងអស់អាចជ្រើសរើសដោយខ្លួនឯងពីការបន្តពាក់ម៉ាស់ ឬមិនពាក់ម៉ាស់។ ប៉ុន្តែ កាតព្វកិច្ចពាក់ម៉ាស់នេះ ត្រូវបន្តអនុវត្តសម្រាប់អ្នកជំងឺកូវីដ-១៩ និងអ្នកដែលមានការពាក់ព័ន្ធនឹងអ្នកវិជ្ជមានកូវីដ-១៩។

២. ប្រជាជនដែលធ្វើដំណើរចេញពីភូមិសាស្ត្រខេត្តទាំង៤ ដែលត្រូវបានលើកលែងកាតព្វកិច្ចពាក់ម៉ាស់ខាងលើ ក៏ដូចជាប្រជាជនទាំងអស់ដែលរស់នៅតាមបណ្តារាជធានី-ខេត្តដទៃទៀត ត្រូវបន្តអនុវត្តកាតព្វកិច្ចពាក់ម៉ាស់ដែលស្ថិតនៅក្នុងវិធានការសុខាភិបាល "**៣ការពារ និង៣កុំ**" ឱ្យបានខ្ជាប់ខ្ជួន រហូតដល់មានសេចក្តីសម្រេចផ្សេងពីនេះ។

៣. គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអាជ្ញាធរខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ ត្រូវយកចិត្តទុកដាក់លើការងារនេះ ដោយត្រូវត្រៀមក្រុមគ្រូពេទ្យ សម្ភារៈបរិក្ខារពេទ្យ និងឱសថព្យាបាលជំងឺកូវីដ-១៩ រួមទាំង ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដើម្បីអាចឆ្លើយតបបានទាន់ពេលវេលាក្នុងករណីដែលមានការផ្ទុះឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ជាយថាហេតុ ក្នុងចំណោមក្រុមប្រជាជននៅក្នុងទីតាំង



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ណាមួយ ព្រមទាំងត្រូវចូលរួមសហការ និងរាយការណ៍ពីករណីសង្ស័យដែលអាចនាំឱ្យមានការផ្ទុះឡើងវិញនៃការឆ្លងវីរុសកូវីដ-១៩។ ជាមួយគ្នានេះ ប្រជាជននៅក្នុងខេត្តទាំង៤ ក៏ត្រូវប្រញាប់ធ្វើតេស្តហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយខ្លួនឯង ក្នុងករណីមានការសង្ស័យ ដូចជាមានរោគសញ្ញាក្តៅខ្លួន ក្អក ឬរោគសញ្ញាផ្លូវដង្ហើមផ្នែកខាងលើ (តឹងច្រមុះ ហៀរសំបោរ រមាស់ក ស្អកក ឈឺក ជាដើម)។

៤. មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តទាំង៤ ត្រូវធ្វើរបាយការណ៍ប្រចាំថ្ងៃពីករណីវិជ្ជមានកូវីដ-១៩ ដែលរកឃើញតាំងពីចាប់ផ្តើមអនុវត្តការលើកលែងកាតព្វកិច្ចពាក់ម៉ាស់នេះ រហូតដល់មានការណែនាំជាថ្មីទៀត ជូនដល់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ខេត្តទាំង៤ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាល ដែលនាយកដ្ឋាននេះ នឹងត្រូវផ្តល់ទិន្នន័យពាក់ព័ន្ធជូនទៅអនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រ ដើម្បីធ្វើការតាមដានវាយតម្លៃស្ថានភាពនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ និងភាពស៊ាំសហគមន៍។ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ នឹងធ្វើបច្ចុប្បន្នភាពពីលក្ខខណ្ឌលើកលែងកាតព្វកិច្ចពាក់ម៉ាស់នេះ យោងតាមភាពចាំបាច់ និងស្ថានភាពវិវត្តន៍ជាក់ស្តែងនៃមេរោគកូវីដ-១៩។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមភារកិច្ចរៀងៗខ្លួន។

សូម ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ម៉ម ប៊ុនហេង

**ចម្លងជូន៖**

- គណៈប្រចាំការនៃ គ.ប.ក.
- គណៈប្រតិបត្តិនៃ គ.អ.ក.
- ឯកសារ-កាលប្បវត្តិ